# ការសម្ភាសន៍របស់អ្នកមីង សោម រ៉េម

កៈ អ្នកសំភាសន៍គង់ ចាន់ណាក់ ខៈ អ្នកដែលត្រូវបានគេសំភាសន៍ សោម រ៉េម

## ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ សោម រ៉េម

សង្ខេបៈ អ្នកមីង សោម រ៉េម គាត់រស់នៅភូមិពោន ឃុំមង់រៀង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ហើយគាត់ជាបងគេក្នុងចំណោមបងប្អូនប្រាំមួយនាក់។ ហើយឪពុកម្តាយរបស់គាត់ត្រូវបានគេយកទៅសំលាប់នៅក្នុងសម័យពលពត ដោយសារឪពុកគាត់ជាមេភូមិចឹងត្រូវបានគេយកទៅសំលាប់ចោល ហើយម្តាយរបស់គាត់ក៏គេយកទៅសំលាប់ដែរដោយខុសគ្នាតែប្រាំពីរថ្ងៃប៉ុណ្ណោះ។ គាត់បានរៀបការជាមួយប្តីរបស់គាត់ក្នុងកំឡុងពេលសម័យសង្គ្រាម ហើយគាត់បានបែកគ្នា ពេលសង្គ្រាមបានចប់ទើបគាត់បានជួយគ្នាវិញ។ ហើយសព្វថ្ងៃនេះគាត់រស់នៅដោយពឹងពាក់លើកូនជាអ្នកផ្គត់ផ្គង់ដល់គាត់ដោយពួកគេបានផ្តល់អោយគាត់ជារៀងរាល់ខែ ដោយសារគាត់ចាស់ហើយមិនអាចរកអ្វីបានទៀតទេ។ធ្វើឡើងនៅភូមិពោន ឃុំមង់រៀវ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ធ្វើឡើងនៅថ្ងៃទី២១ ខែ០៤ ឆ្នាំ២០១៨។

កៈ អញ្ចឹង មុនដំបូងជំរាបសួរអ្នកមីង ខ្ញុំបាទឈ្មោះគង់ ចាន់ណាក់ មកពីគម្រោងជីវប្រវត្តិផ្ទាល់ខ្លួន របស់ប្រជាជនកម្ពុជាដែលធ្វើឡើងដោយសាកលវិទ្យាល័យ ប៊ី វ៉ាយ យូ នៅសហរដ្ឋអាមេរិច ដោយ សារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាប្រវត្តិរបស់ប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយពួកគេបានស្គាល់ពីប្រវត្តិរបស់ដូនតាហើយនឹងឪពុកម្តាយរបស់ពួកគេ។ ហើយការ សម្ភាសន៍នេះយើងធ្វើនៅថ្ងៃទី២១ ខែ០៤ ឆ្នាំ២០១៨ ហើយយើងធ្វើនៅភូមិពោន ឃុំមង់រៀវ ស្រុក ត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។ ហើយការសម្ភាសន៍នេះយើងនឹងថតជាសំលេងហើយនឹងថតរូបភាពរបស់ អ្នកមីងហើយផ្ញើរទៅកាន់សកលវិទ្យាល័យដើម្បីយើងអាចដាក់នៅលើវេបសាយរបស់សាកលវិទ្យា ល័យ ហើយអញ្ចឹង

តើអ្នកមីងយល់ព្រមអោយពួកយើងយកសំលេងហើយនឹងរូបភាពរបស់អ្នកមីង ដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យដែរទេ អ្នកមីង?

ខ៖ អោយយកទៅដាក់ទៅ។

ក៖
អញ្ចឹងអរគុណអ្នកមីងដែលបានអនុញ្ញាតិអោយយើងយកសំលេងហើយនឹងរូបភាពរបស់អ្នកមីង ដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យ។ អញ្ចឹងជាដំបូងខ្ញុំសុំសួរអ្នកមីង តើអ្នកមីងមាន ឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ខ្ញុំឈ្មោះសោម រ៉េម។

ក៖ អ្នកមីងឈ្មោះសោម រ៉េម។ ហើយអញ្ចឹង តើអ្នកមីងមានឈ្មោះហៅក្រៅទេ អ្នកមីង?

ខ៖ អត់មានឈ្មោះហៅក្រៅទេ។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីង កាលអ្នកមីងនៅក្មេងៗ តើគេហៅឈ្មោះអ្នកមីងថាម៉េចដែរ អ្នកមីង?

ខ៖ ក្មេងៗគេហៅថាម៉េច ដូចអត់យល់?

ក៖ ដូចថា កាលដែលអ្នកមីងនៅក្មេងៗ អ្នកជិតខាង ឬក៏បងប្អូនអី ច្រើនហៅឈ្មោះអ្នកមីងថាម៉េច ដែរអ្នកមីង?

ខ៖ ហៅឈ្មោះសោម រ៉េម នឹងដដែល មានតែឈ្មោះមួយនឹងទេ មិនដែលមានឈ្មោះពីបីទេ។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីង សព្វថ្ងៃនេះអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ៖ ឆ្នាំនឹងខ្ញុំមានអាយុហុកសិបប្រាំឆ្នាំហើយ។

ក៖ អ្នកមីងមានអាយុហុកសិបប្រាំឆ្នាំហើយអ្នកមីង។ ហើយអញ្ចឹង តើអ្នកមីងមាននៅចាំថាអ្នកមីងកើតនៅក្នុងឆ្នាំណាទេអ្នកមីង?

ខ៖ អត់ដឹងផង ដឹងតែថាមានអាយុហុកសិបប្រាំឆ្នាំ។

ក៖ ដឹងតែថាអាយុហុកសិបប្រាំឆ្នាំណអ្នកមីងណ!
ហើយអញ្ចឹងមានន័យថាអ្នកមីងបានកើតក្នុងអំឡុងឆ្នាំមួយពាន់ប្រាំបួនរយហាសិបបី។ ហើយអញ្ចឹង តើអ្នកមីងកើតនៅក្នុងឆ្នាំណា សំរាប់ឆ្នាំខ្មែរយើង អ្នកមីង?

ខ៖ ខ្ញុំកើតឆ្នាំមមី។

ក៖ អ្នកមីងកើតឆ្នាំមមី។ ហើយអញ្ចឹងតើអ្នកមីងកើតនៅខេត្តណាដែរអ្នកមីង?

ខ៖ ខ្ញុំកើតនៅខេត្តត្បូងឃ្មុំ។

ក៖ អូ! អ្នកមីងបានកើតនៅខេត្តត្បូងឃ្មុំយើងនឹងតែម្តង។ ហើយអញ្ចឹង
តើអ្នកមីងកើតនៅភូមិ ឃុំ ស្រុកណាដែរ អ្នកមីង?

ខ៖ ខ្ញុំកើតនៅភូមិពណ្ណរាយ ឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

ក៖ ហ្នឹងហើយ! ហើយអញ្ចឹងសំរាប់អ្នកមីង
តើអ្នកមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ្នកមីង?

ខ៖ ខ្ញុំមានបងប្អូនចំនួនប្រាំមួយនាក់។

ក៖ អ្នកមីងមានបងប្អូនប្រាំមួយនាក់។ ហើយអញ្ចឹង
តើអ្នកមីងជាកូនទីប៉ុន្មាននៅក្នុងក្រុមគ្រួសាររបស់អ្នកមីង?

ខ៖ ខ្ញុំជាកូនទីមួយនៅក្នុងក្រុមគ្រួសារ។

ក៖ អូ! អ្នកមីងជាកូនទីមួយ អញ្ចឹងមានន័យថាអ្នកមីងជាបងគេនៅក្នុងក្រុមគ្រួសារ។
ហើយអញ្ចឹង សំរាប់បងប្អូនរបស់អ្នកមីង តើមានប្រុសប៉ុន្មាននាក់ ហើយស្រីប៉ុន្មាននាក់?

ខ៖ ខ្ញុំមានបងប្អូនប្រុសមួយនាក់ ហើយស្រីប្រាំនាក់។

ក៖ ប្រុសមួយនាក់ ហើយស្រីប្រាំនាក់។ ហើយអញ្ចឹង
តើអ្នកមីងអាចជួយរៀបរាប់ឈ្មោះរបស់បងប្អូនរបស់អ្នកមីងទាំងអស់បានទេ?

ខ៖ សោម រ៉េម, សោម រ៉ែម, សោម ឆែម, សោម ឆន, សោម រឿន និង សោម ឆ័យ។

ក៖ អរគុណអ្នកមីង! ហើយអញ្ចឹង អ្នកមីងមាននៅចាំសាច់រឿងអ្វីខ្លះអំពីពួកគាត់ដែរទេ
អ្នកមីង?

ខ៖ អត់ចាំផង។

ក៖ ហើយអញ្ចឹងនៅពេលដែលអ្នកមីងនៅក្មេងៗតើអ្នកមីងចូលចិត្តធ្វើអ្វីខ្លះជាមួយពួកគាត់
អ្នកមីង?

ខ៖ ដូចគ្មានធ្វើអីទេ មានតែធ្វើការជាមួយឪពុកម្ដាយតែម្ដង គ្មានលេងសើចអីជាមួយបងប្អូនទេ បងប្អូនគ្មានចេះលេងសើចសោះតែម្ដង។

ក៖ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះបងប្អូនរបស់អ្នកមីង តើពួកគាត់រស់នៅកន្លែងណាដែរអ្នកមីង?

ខ៖ ពួកគាត់រស់នៅឆ្ងាយៗណាស់ ខ្លះរស់នៅរតនៈគីរី ខ្លះប៉ោយប៉ែត វាមិនជិតគ្នាទេ ខ្លះស្នួល ខ្លះក្រចេះអីចឹងទៅណា វាឆ្ងាយៗពីគ្នា។

ក៖ ឆ្ងាយៗពីគ្នា អញ្ចឹងមានន័យថាពួកគាត់ចេញទៅរស់នៅតាមខេត្តផ្សេងៗ។ ហើយអញ្ចឹងដោយតែពួកគាត់មានគ្រួសារនៅទីនោះ ឬមួយយ៉ាងណាដែរអ្នកមីង?

ខ៖ ពួកគេទៅរកស៊ីនៅនឹងទៅ ហើយគេរកបានចឹងទៅ គេទិញដីទិញផ្ទះនៅនឹងទៅណា ហើយយើងនៅនឹងទៅ នៅចាំស្រុក យើងមិនដឹងទៅខាងណាមកខាងណា បើខ្លួនវាចាស់ហើយ មិនដឹងជាទៅខាងណា នៅនឹងភូមិនឹងទៅ។

ក៖ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះបងប្អូនរបស់អ្នកមីង តើពួកគាត់ធ្វើការងារអ្វីដែរអ្នកមីង?

ខ៖ ពួកគាត់ធ្វើស្រែ ធ្វើចំការ ជៀរជ័រអីចឹងទៅណា និយាយទៅស៊ីឈ្នួលអោយគេតែម្ដង។

ក៖ ហ្នឹងហើយ! ធ្វើការស៊ីឈ្នួលគេ! ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងមានចាំទេថា តើឪពុករបស់អ្នកមីង គាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំគាត់ឈ្មោះ សោម វេន។

ក៖ ឪពុករបស់អ្នកមីងឈ្មោះ សោម វេន។ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ តើគាត់មានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ៖ គាត់ស្លាប់បាត់យូរហើយ។

ក៖ អូ! គាត់បានស្លាប់បាត់យូរហើយ។ ហើយអញ្ចឹង តើឪពុករបស់អ្នកមីងគាត់ស្លាប់ប្រហែលប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ គាត់ស្លាប់តាំងពីជំនាន់ពលពតមកម្លេះ គាត់ស្លាប់តាំងពីឆ្នាំមួយពាន់ប្រាំបួនរយចិតបីមកម្លេះ។

ក៖ អូ! គាត់ស្លាប់តាំងពីមួយពាន់ប្រាំបួនរយចិតសិបបី។ ហើយអញ្ចឹង នៅពេលដែលឪពុកអ្នកមីង គាត់បានស្លាប់ តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ នៅពេលគាត់ស្លាប់ខ្ញុំមានអាយុដប់ប្រាំបួនឆ្នាំ។

ក៖ អូ! ពេលគាត់បានស្លាប់អ្នកមីងមានអាយុដប់ប្រាំបួនឆ្នាំ។
តើគាត់ស្លាប់ជំនាន់អាពតនឹងដោយសារអ្វីដែរអ្នកមីង?

ខ៖ ដោយសារអាពតយកគាត់ទៅវាយចោលតែម្ដង និយាយអោយត្រង់ទៅ។

ក៖ ហើយអញ្ចឹង តើម្ដាយរបស់អ្នកមីង គាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខ៖ ម្ដាយរបស់ខ្ញុំគាត់ឈ្មោះ យុត យ៉ែម។

ក៖ យុត យ៉ែម! ហើយអញ្ចឹង តើអ្នកមីងមាននៅចាំទេថា
តើម្ដាយរបស់អ្នកមីងគាត់បានកើតនៅពេលណាទេ អ្នកមីង?

ខ៖ អត់ដឹងទេ។

ក៖ ហើយអញ្ចឹង អ្នកមីងនៅចាំទេថា ពេលដែលអ្នកមីងកើត
តើម្ដាយរបស់អ្នកមីងគាត់មានអាយុប្រហែលប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ អត់ដឹងអាយុប៉ុន្មានទេនឹង អត់ដឹងសោះតែម្ដង។

ក៖ អត់ដឹងសោះតែម្ដង! ហើយអញ្ចឹង
តើម្ដាយរបស់អ្នកមីងគាត់កើតនៅក្នុងឆ្នាំខ្មែរឆ្នាំអីដែរអ្នកមីង?

ខ៖ អត់ដឹងគាត់កើតឆ្នាំអីទេ។

ក៖ អត់ដឹងគាត់កើតឆ្នាំអីទេ! ហើយអញ្ចឹង តើម្ដាយរបស់អ្នកមីង
គាត់ស្លាប់ប្រហែលជាឆ្នាំណាដែរ អ្នកមីង?

ខ៖ គាត់ស្លាប់ប្រហែលឆ្នាំមួយពាន់ប្រាំបួនរយចិតសិបបីនឹង
គេយកគាត់ទៅសំលាប់ចោល។

ក៖ អញ្ចឹងមានន័យថាម្ដាយរបស់អ្នកមីង ហើយឪពុករបស់អ្នកមីង
គេសំលាប់ទាំងពីរនាក់នៅក្នុងឆ្នាំជាមួយគ្នាតែម្ដង។

ខ៖ ខុសត្រូវគ្នាប្រាំពីរថ្ងៃ។

ក៖ អូ! ខុសត្រូវគ្នាតែប្រាំបីថ្ងៃទេអ្នកមីង។
ហើយអញ្ចឹងកាលឪពុកម្ដាយរបស់អ្នកមីងគាត់នៅរស់
តើពួកគាត់ប្រកបមុខរបរអ្វីចិញ្ចឹមជីវិតដែរ អ្នកមីង?

ខ៖ ពួកគាត់ជៀរជ័រកៅស៊ូ ស៊ីឈ្នួលគេ។

ក៖ ហើយអញ្ចឹង តើឪពុករបស់អ្នកមីងគាត់ជាមនុស្សយ៉ាងម៉េចដែរអ្នកមីង សំរាប់ចរិត?

ខ៖ ចរិតឫកពាគាត់ត្រឹមត្រូវស្លូតបូតណាស់ ប៉ុន្តែគេអោយធ្វើប្រធានភូមិអីចឹងណា
ដល់ចឹងទៅគេយកគាត់ទៅសំលាប់ចោល។

ក៖ ហើយអញ្ចឹង សំរាប់ម្តាយរបស់អ្នកមីង តើគាត់មានចរិយាយ៉ាងដូចម្តេចដែរអ្នកមីង?

ខ៖ ម្តាយគាត់ក៏មិនអីដែរ គាត់ត្រឹមត្រូវស្លូតបូតដែរនឹង
គាត់អត់មានចេះពាក្យសំដីអីអាក្រក់ដាក់អ្នកជិតខាងទេ គាត់ស្លូតណាស់។

ក៖ ហើយអញ្ចឹង តើឪពុកម្តាយរបស់អ្នកមីងពួកគាត់មានធ្លាប់ប្រាប់អ្នកមីងអំពីជីវិតគាត់
កាលគាត់នៅក្មេងៗទេ អ្នកមីង?

ខ៖ អត់ដឹង គាត់មិនដែលនិយាយប្រាប់ផង។

ក៖ អូ! គាត់មិនដែលនិយាយប្រាប់អ្នកមីងទេ។ ហើយអញ្ចឹង
តើអ្នកមីងគាត់មានអនុស្សាវរីយ៍អ្វីល្អៗ ជាមួយឪពុកម្តាយរបស់អ្នកមីងទេ?

ខ៖ មាន ស្រឡាញ់ពេញចិត្តគាត់ ស្រឡាញ់គាត់ណាស់
មិនដែលមានសំដីធ្ងន់ដាក់ឪពុកម្តាយទេ។

ក៖ ហើយអញ្ចឹង តើអ្នកមីងមាននៅចាំឈ្មោះជីដូនជីតារបស់អ្នកមីងខាងឪពុកទេ?

ខ៖ អត់ចាំទេ ព្រោះអីពេលយើងកើតមកអត់ដែលឃើញផង
មិនដែលឃើញហើយមិនដែលលឺគេហៅទៀត ព្រោះអីគាត់នៅស្រុកឆ្ងាយ
ហើយឪពុកខ្ញុំគាត់បានមកដល់ទីនេះហើយយកប្រពន្ធនៅនឹង ខាងម្តាយក៏មិនដឹង
ខាងឪពុកក៏មិនដឹង។

ក៖ អញ្ចឹងអ្នកមីងអត់ស្គាល់ជីដូនជីតាខាងឪពុក
ហើយខាងម្តាយដោយសារពេលដែលអ្នកមីងកើតមកអត់មានពួកគាត់ទេ។

ខ៖ អត់ អត់មានឃើញទាំងអស់។

ក៖ ហើយអញ្ចឹង
សំរាប់គ្រួសាររបស់អ្នកមីងរស់នៅខេត្តនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ៖ ខ្ញុំរស់នៅខេត្តនេះតាំងពីខ្ញុំកើតមក។

កៈ អូ! អញ្ចឹងអ្នកមីងរស់នៅខេត្តនឹងតាំងពីអ្នកមីងកើតមកតែម្តង។

ខៈ តាំងពីកើតតែម្តង រស់នៅតែនឹងស្រុកនឹង មិនដែលទៅនៅណាឆ្ងាយពីនឹងទេ។

កៈ ហើយអញ្ចឹង តើអ្នកមីងមានសាច់ញាត្តិដទៃទៀតដែលរស់នៅក្រៅប្រទេសខ្មែរទេ?

ខៈ អត់មានទេ។

កៈ អត់មានទេ! ហើយអញ្ចឹង តើស្វាមីរបស់អ្នកមីង គាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខៈ ស្វាមីរបស់ខ្ញុំគាត់ឈ្មោះ ពៅ អាន។

កៈ ហើយអញ្ចឹង តើអ្នកមីងមាននៅចាំទេថា
អ្នកមីងបានរៀបការជាមួយគាត់នៅពេលណាទេ អ្នកមីង?

ខៈ ខ្ញុំរៀបការជាមួយគាត់ពេលដែលខ្ញុំមានអាយុម្ភៃពីរឆ្នាំ។

កៈ អូ! អ្នកមីងបានរៀបការពេលអ្នកមីងអាយុម្ភៃពីរឆ្នាំ។

ខៈ នឹងហើយខ្ញុំអាយម្ភៃពីរឆ្នាំ ហើយតាអាយុម្ភៃប្រាំពីរឆ្នាំ។

កៈ ហើយអញ្ចឹង តើអ្នកមីងចាំទេថា អ្នកមីងរៀបការនឹងប្រហែលជាឆ្នាំណាដែរ អ្នកមីង?

ខៈ អូ! មិនដឹងជាឆ្នាំណាទេ។

កៈ ហើយអញ្ចឹង បើគិតទៅ អ្នកមីងហើយនឹងគាត់
មកដល់សព្វថ្ងៃនេះតើអ្នកមីងបានរៀបការបានប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខៈ មិនដឹងជាប៉ុន្មានឆ្នាំទេ ប្រហែលជា សាម សែសិបឆ្នាំហើយ។

កៈ ហើយអញ្ចឹង សំរាប់ប្តីរបស់អ្នកមីង តើសព្វថ្ងៃនេះគាត់មានអាយុប៉ុន្មានឆ្នាំហើយ
អ្នកមីង?

ខៈ ប្តីរបស់ខ្ញុំគាត់មានអាយុចិតសិបឆ្នាំហើយ។

កៈ ហើយអញ្ចឹង តើអ្នកមីងចាំទេថា លោកពូគាត់កើតឆ្នាំណាក្នុងឆ្នាំខ្មែរយើង?

ខៈ អត់ដឹងទេ។

កៈ អត់ដឹងទេ! ហើយអញ្ចឹង សំរាប់អាពាហ៍ពិពាហ៍នឹង
ត្រូវបានរៀបចំឡើងដោយឪពុកម្តាយ ឬមួយអ្នកមីងរៀបចំឡើងដោយខ្លួនឯង?

ខ៖ ញាត្តិជិតខាងគាត់អ្នករៀបចំអោយ ព្រោះអីឪពុកម្ដាយគាត់ស្លាប់អស់ហើយ។

ក៖ អញ្ចឹង ញាត្តិជិតខាងពួកគាត់អាណិតស្រឡាញ់យើងទៅ គាត់ជួយរៀបចំអោយយើង។ ពេលដែលរៀបចំអាពាហ៍ពិពាហ៍នឹង តើមានថ្លៃជំនួនដែរទេអ្នកមីង?

ខ៖ មានដែលថ្លៃជំនួននោះ។

ក៖ ហើយអញ្ចឹង ថ្លៃជំនួនកាលនោះ ប្រហែលប៉ុន្មានដែរ អ្នកមីង?

ខ៖ យើងនិយាយថា បីបួនរយកាលនោះក៏វាថ្លៃដែលណា។

ក៖ បីបួនរយលុយរៀលខ្មែរយើងនឹងឬ?

ខ៖ ហ្នឹងហើយ លុយរៀលយើងកាលជំនាន់នឹងថ្លៃដែរណា។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីង តើអ្នកមីងគិតថា ជីវិតអ្នកមីងមុនរៀបការ ហើយនឹងក្រោយរៀបការ មានភាពខុសប្លែកគ្នាទេ អ្នកមីង?

ខ៖ ខុសគ្នាម៉េចទេ?

ក៖ ចង់និយាយថា ជីវិតយើងធ្លាប់ នៅលីវ ហើយនៅពេលរៀបការហើយមានភាពខុសគ្នាទេ?

ខ៖ ខុសគ្នា វាមិនមែនថាវាមិនខុសគ្នាទេ កាលនៅលីវនឹងវាពិបាកដូចថាម៉ែឪរបស់យើងគេសំលាប់ ចោលអស់ចឹងយើងវាពិបាកហើយ ពេលយើងមានប្ដីមានប្រពន្ធចឹងទៅយើងបាននាំគ្នារកស៊ី យើងមានគ្នា។

ក៖ ហើយអញ្ចឹង សំរាប់ចំណងអាពាហ៍ពិពាហ៍របស់អ្នកមីង តើមានកូនចំនួនប៉ុន្មាននាក់ដែរអ្នកមីង?

ខ៖ ខ្ញុំមានកូនបីនាក់។

ក៖ អ្នកមីងមានកូនបីនាក់។ ហើយអញ្ចឹង កូនរបស់អ្នកមីង តើមានប្រុសប៉ុន្មាននាក់ ហើយស្រីប៉ុន្មាននាក់ដែរ អ្នកមីង?

ខ៖ ប្រុសមួយនាក់ ហើយស្រីពីរនាក់។

ក៖ ប្រុសមួយនាក់ ហើយស្រីពីរនាក់។ ហើយអញ្ចឹង តើអ្នកមីងអាចជួយរៀបរាប់ឈ្មោះកូនទាំងបីនាក់របស់អ្នកមីងផងបានទេ អ្នកមីង?

ខ៖ ទីមួយឈ្មោះ ពៅ ស្រៀន ទីពីរឈ្មោះ ពៅ សុខន ហើយទីបីឈ្មោះ ពៅ សុខា។

ក៖ ហើយអញ្ចឹង កូនទៅមួយរបស់អ្នកមីង
តើសព្វថ្ងៃនេះគាត់មានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ៖ កូនទីមួយរបស់ខ្ញុំគាត់មានអាយុសែសិបប្រាំឆ្នាំហើយ។

ក៖ សែសិបប្រាំឆ្នាំហើយ។ ហើយចុះកូនទីពីររបស់អ្នកមីង
តើគាត់មានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ៖ កូនទីពីររបស់ខ្ញុំគាត់មានអាយុសាមសិបប្រាំមួយឆ្នាំហើយ។

ក៖ ហើយចុះសំរាប់កូនទីបីរបស់អ្នកមីង តើគាត់មានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ៖ កូនទីបីរបស់ខ្ញុំគាត់មានអាយុសាមសិបបួនឆ្នាំហើយ។

ក៖ ហើយអញ្ចឹង តើអ្នកមីងបានរៀបការជាមួយលោកពូបានប៉ុន្មានឆ្នាំ
ទើបអ្នកមីងមានកូនទីមួយ?

ខ៖ រៀងយូរដែលនឹងណា កូនថាបានរៀងយូរព្រោះអីកើតមកស្លាប់ កើតមកស្លាប់។

ក៖ ហើយកូនអ្នកមីងដែលកើតមកស្លាប់នឹង ប៉ុន្មាននាក់ដែរអ្នកមីង?

ខ៖ បីបួននាក់ដែរណា។

ក៖ អូ! អញ្ចឹងណ៎ ស្តាយណាស់អ្នកមីង។

ខ៖ អើយ ជំនាន់នឹងក្មួយអើយ ជំនាន់ពលពតនឹងគ្មានពេទ្យមានអីណា ហូបតែបានកក
ហើយដល់ពេលយើងមានបញ្ហាយើងមានថ្នាំមកពីណាដើម្បីព្យាបាល។

ក៖ ហ្នឹងហើយ! អញ្ចឹងទៅធ្វើអោយយើងអត់មានជីវជាតិគ្រប់គ្រាន់
ចឹងកូនរបស់យើងអត់មានសុខភាពល្អ ដល់ពេលគាត់កើតគាត់មានបញ្ហា។ ហើយអញ្ចឹង
តើអ្នកមីងចេះអាន និងសរសេរអក្សរខ្មែរដែរទេអ្នកមីង?

ខ៖ អត់ចេះទេ ជំនាន់នោះ។

ក៖ អត់ចេះទេអ្នកមីង! ហើយអញ្ចឹង
តើអ្នកមីងចេះនិយាយភាសាផ្សេងក្រៅពីភាសាខ្មែរដែរទេអ្នកមីង?

ខ៖ អត់ចេះទេ។

កៈ ហើយអញ្ចឹង តើអ្នកមីងបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរ អ្នកមីង?

ខៈ អត់បានរៀនទេ។

កៈ អូ! អញ្ចឹងអ្នកមីងអត់ដែលបានរៀនសោះតែម្តង។

ខៈ អត់ដែលបានរៀនសោះតែម្តង។

កៈ ហើយអញ្ចឹង តើអ្នកមីងមានមិត្តភក្តិស្និតស្នាលដែលធំធាត់មកជាមួយគ្នាដែរទេអ្នកមីង?

ខៈ អត់មានទេ មិនដែលមានមិត្តភក្តិមកពីណាទេ មិនចេះតែម្តង។

កៈ អត់តែមានទេអ្នកមីង។ ហើយអញ្ចឹង តើអ្នកមីងមានធ្វើស្រែចំការទេសព្វថ្ងៃនេះ?

ខៈ អត់មានទេ។

កៈ អត់មានទេ! ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ តើអ្នកមីងធ្វើអ្វីដែរសំរាប់ចិញ្ចឹមជីវិត?

ខៈ អត់មានធ្វើអ្វីទាំងអស់ សព្វថ្ងៃនេះបានកូនជួយ។

កៈ អូ! អញ្ចឹងមានន័យថា កូនរបស់អ្នកមីងគាត់ជាអ្នកផ្តល់មកផ្គត់ផ្គង់ដល់អ្នកមីង។ ហើយអញ្ចឹង សំរាប់អ្នកមីងគិតថាជីវិតរបស់អ្នកមីងតាំងពីក្មេង រហូតមកដល់ចាស់ តើជីវិតរបស់អ្នកមីងមានការផ្លាស់ប្តូរដែរឬទេអ្នកមីង?

ខៈ ផ្លាស់ប្តូរ កាលពីមុនយើងធ្វើការហាត់អីចឹងទៅណា កាលយើងនៅក្មេង តែឥឡូវបានកូនគេផ្តល់អោយយើងមួយខែម្តង បានកូនគេផ្តល់អោយដើម្បីរស់នៅរាល់ថ្ងៃនឹង បើខ្លួនឯងវិញគ្មានទេរាល់ថ្ងៃនឹងរកអីកើត យើងអាយុហុកសិបជិតចិតសិបហើយនឹង។

កៈ អញ្ចឹងបានន័យថា កូនៗគាត់ដឹងគុណចឹងហើយគាត់ផ្តល់អោយជារៀងរាល់ខែអោយអ្នកមីង។ ហើយអញ្ចឹង តើមានម្ហូបណាដែលអ្នកមីងចូលចិត្តហូបជាងគេទេអ្នកមីង?

ខៈ មានតែត្រីងៀត នឹងចូលចិត្តហូបជាងគេហើយ។

កៈ ហ្នឹងហើយ! ត្រីងៀតអាំងចឹងទៅ។ ហើយអញ្ចឹងសំរាប់ល្បែងប្រជាប្រិយខ្មែរយើង តើមានល្បែងណាដែលអ្នកមីងចូលចិត្តលេងទេអ្នកមីង?

ខៈ បើនិយាយចឹង ដូចជាមិនដែលចេះរាំចេះលេងអីនឹងគេទេ មិនដែលចេះលេងនឹងគេសោះ។

ក៖ មិនដែលចេះលេងនឹងគេទេ។ ហើយអញ្ចឹងសំរាប់បទចម្រៀងវិញអ្នកមីង តើមានបទចម្រៀងណាដែលអ្នកមីងចូលចិត្តស្ដាប់ហើយរៀនច្រៀងតាមតាំងពីក្មេងមកទេអ្នកមីង?

ខ៖ អត់ចេះសោះ។

ក៖ អូ! អត់ចេះសោះតែម្ដង។ ហើយអញ្ចឹង តើមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ្នកមីងដែលចេះលេងឧបករណ៍ភ្លេងដែរឬទេអ្នកមីង?

ខ៖ អត់មានទេ។

ក៖ អត់មានទេ! ហើយអញ្ចឹង តើផ្ទះរបស់អ្នកមីងមានលក្ខណៈដូចម្ដេចដែរអ្នកមីង តាំងពីតូចមក?

ខ៖ ពីក្មេងពីតូចមានតែផ្ទះនៅក្នុងចំការកៅស៊ូនឹងណា មានតែផ្ទះយើងស៊ីឈ្នួលគេ។

ក៖ ហើយអញ្ចឹង តើផ្ទះនឹងគេអោយយើងនៅ ឬមួយយ៉ាងម៉េចដែរអ្នកមីង?

ខ៖ ផ្ទះនឹងគេអោយយើងនៅដោយសារយើងស៊ីឈ្នួលគេ យើងជៀរជ័រចឹងហើយគេអោយយើងនៅ ដល់ពេលយើងអស់ការងារទៅ គេអោយយើងចេញហើយ។

ក៖ ហើយអញ្ចឹង តើអ្នកមីងអត់មានផ្ទះផ្ទាល់ខ្លួនទេអ្នកមីង?

ខ៖ អត់មានទេ។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីង តើអ្នកមីងមានជំនាញដែលបន្តវេនពីក្រុមគ្រួសារទេ ដូចជាវេញល្បើផ្ដៅ ឬក៏ជំនាញក្នុងការធ្វើស្ករត្នោតអីទេអ្នកមីង?

ខ៖ អត់មានទេ។

ក៖ អត់មានទេ! ហើយអញ្ចឹង តើអ្នកមីងអាចប្រាប់ខ្ញុំបានទេ ពីពេលដែលលំបាកជាងគេនៅក្នុងជីវិតរបស់អ្នកមីង?

ខ៖ ពេលលំបាកជាងគេមានតែជំនាន់ពលពតនឹង គេសំលាប់គេកាប់នឹង វាលំបាកមែនទែនតែម្ដង កាលនោះវាលំបាកណាស់ តែឥលូវវាបានធូរបានកូនជួយចិញ្ចឹមប៉ុននឹងទេ បើថាចំណែកអោយយើងរកស៊ីអីនោះវាគ្មានទេ ព្រោះយើងចាស់ចំណាស់នឹងហើយ

មិនដឹងទៅរកអីទេ ហើយជើងពិការមួយចំហៀងទៀតនោះ
វាមិនដឹងថារកអីទេរាល់ថ្ងៃនឹង។

ក៖ ហើយអញ្ចឹង
តើអ្នកមីងអាចជួយរៀបរាប់ជីវិតរបស់អ្នកមីងនៅក្នុងសម័យសង្រ្គាមបានទេ?
ថាអ្នកមីងបាននៅកន្លែងណា ហើយពួកគេបានអោយអ្នកមីងធ្វើអីគេខ្លះ
ហើយធ្វើម៉េចបានអ្នកមីងផុតទុក្ខ?

ខ៖ កាលសម័យសង្រ្គាមនឹងគេអោយយើងលើកដី ជីកប្រឡាយ គេអោយយើងនឹង
ហើយនឹងក្រុមគ្រួសារយើងនឹងទៅកិនស្រូវនៅក្នុងព្រៃកុំអោយគេឃើញចឹងណា
កិនស្រូវទៅ លាក់ៗខ្លួនទៅបានជារស់ដល់សព្វថ្ងៃនឹងទៅ
កុំអីនឹងស្លាប់បាត់ទៀតទៅហើយ។

ក៖ ហើយអញ្ចឹង កាលក្នុងសម័យសង្រ្គាមនឹង តើអ្នកមីងមានស្វាមីហើយ
ឬក៏មិនទាន់មានទេអ្នកមីង?

ខ៖ កាលក្នុងសម័យសង្រ្គាមនឹងខ្ញុំមានស្វាមីហើយតើ ប៉ុន្តែយើងវាបែកគ្នាមួយគ្រា
ដល់យើងបែកគ្នាចឹងទៅទើបនឹងជួបគ្នាវិញទេ។

ក៖ អញ្ចឹងមានន័យថា អ្នកមីងមានស្វាមីនឹងមុនសង្រ្គាមទៀត
តែដល់សង្រ្គាមមកយើងបែកគ្នា។

ខ៖ កាលសង្រ្គាមនឹងយើងវានៅក្រមុំ
ដល់បានពាក់កណ្តាលសង្រ្គាមនឹងក៏យើងបានរៀបការ
ហើយដល់រៀបការហើយចឹងក៏វាបែកគ្នា
ដល់ពេលដែលសង្រ្គាមចប់ទើបយើងបានជួបគ្នាវិញ។

ក៖ ហើយអញ្ចឹងតើអ្នកមីងធ្លាប់មានបទពិសោធន៍ល្អៗដូចជា រៀបការកូន រៀបការចៅ
ឬមួយរៀបការបងប្អូនអីទេអ្នកមីង?

ខ៖ មាន មានរៀបការកូន រៀបការចៅ រៀបការបងប្អូននៅលើខ្លួនយើងទាំងអស់នឹង។

ក៖ ហើយអញ្ចឹង ពេលមានកម្មវិធីនឹងម្តងៗ តើអ្នកមីងមានអារម្មណ៍ដូចម្តេចដែរអ្នកមីង?

ខ៖ មានអារម្មណ៍សប្បាយខ្លះទៅ មានអារម្មណ៍គិតថាគ្មានម៉ែគ្មានឪខ្លះទៅ
ម៉្យាងទៅនឹងឃើញអាណិតម៉ែឪចឹងទៅ ម៉្យាងទៅនឹកឃើញថាកូនបានរៀបការ
ប្អូនបានរៀបការ ម៉្យាងយើងគ្មានម៉ែឪអង្គុយក្បាលកន្ទេលយើងក៏កំសត់ដែរ។

កៈ ហើយអញ្ចឹង ពេលដែលអ្នកមីងនៅក្មេង
តើអ្នកមីងធ្លាប់មានសេចក្តីសង្ឃឹមថាអ្នកមីងចង់ធ្វើអ្វីទេ
នៅពេលដែរអ្នកមីងធំឡើងចឹងណា?

ខៈ ពេលនៅក្មេងមានសង្ឃឹមថាចង់ជួយឪពុកម្តាយកាលនោះ ព្រោះអីឪពុកម្តាយកូនច្រើន
មានអីស្លាប់អស់នៅសល់តែប្រាំមួយនាក់នឹងទៅ
គ្មានសង្ឃឹមអីក្រៅពីជួយឪពុកព្រោះអីឪពុកតែម្នាក់ឯងកូនច្រើន
ម្លោះហើយដល់ពេលបែកចឹងទៅប្អូនក៏ស្លាប់អស់ទៅ ក៏បែកគ្នាអស់ចឹងទៅ។

កៈ ហើយអញ្ចឹង បើសិនជាអ្នកមីងផ្តាំផ្ញើរទៅកូនចៅជំនាន់ក្រោយ
តើអ្នកមីងនឹងផ្តាំផ្ញើរអ្វីខ្លះទៅកាន់កូនចៅជំនាន់ក្រោយ?

ខៈ ផ្តាំផ្ញើរទៅកូនចៅជំនាន់ក្រោយអោយកាន់តែអំពើល្អ
កុំអោយកាន់អំពើអាក្រក់ចឹងទៅណា អោយយើងកាន់អំពើល្អទៅ បានរស់បានយូរ។

កៈ ហើយអញ្ចឹង បើសិនអ្នកមីងចង់អោយកូនចៅជំនាន់ក្រោយជៀសវាង
តើអ្នកមីងចង់អោយពួកគាត់ជៀសវាងពីអ្វីខ្លះដែរអ្នកមីង?

ខៈ អោយជៀសវាងពីគ្រឿងញៀន ជៀសវាងពីអំពើឃោឃៅអីចឹងទៅណា។

កៈ ហើយអញ្ចឹងសំរាប់ខ្ញុំអ្នកមីង
អរគុណច្រើនសំរាប់អ្នកមីងដែលបានផ្តល់ពេលវេលាអោយខ្ញុំបានសម្ភាសន៍ពីខ្សែជីវិតរប
ស់អ្នកមីង ជាខ្សែជីវិតដ៏លំបាកអីចឹងណាអ្នកមីង ហើយចុងក្រោយខ្ញុំសូមជូនពរដល់អ្នកមីង
សូមអោយអ្នកមីងមានសុខភាពល្អ មានកំលាំងមាំមួន
ហើយជូនពរថាកូនចៅរបស់អ្នកមីងនឹងមានសុខភាពល្អ
ហើយមានកំលាំងដើម្បីបន្តនូវមុខរបរការងារ
ហើយនឹងជោគជ័យរាល់បំណងប្រាថ្នាទាំងអស់
ដើម្បីគាត់អាចជួយអ្នកមីងក្នុងជីវិតមនុស្សចាស់អោយមានសេចក្តីសុខ។
អរគុណច្រើនអ្នកមីង។